# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែកក្កដា ឆ្នាំ២០១៤
## និងទិសដៅការងារ ខែសីហា ឆ្នាំ២០១៤

(ពីថ្ងៃទី២៦/០៦/២០១៤ ដល់ ២៥/០៧/២០១៤)

ដោយផ្អែកលើផែនការសកម្មភាពអនុវត្តទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ឆមាសទី២ ឆ្នាំ២០១៤ និង ទិសដៅការងារ ដែលបានដាក់ចេញកាលពីខែមិថុនា ឆ្នាំ២០១៤ កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីរួមចំណែកអនុវត្ត " គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋទទួលបានលទ្ធផលដូចខាងក្រោម ៕

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

តាមរបាយការណ៍របស់អង្គភាពអនុវត្តន៍ច្បាប់ រួមមាន មន្ទីរប្រឆាំងគ្រឿងញៀន, ស្នងការដ្ឋាននគរបាល និងកងរាជអាវុធហត្ថ រាជធានី-ខេត្ត ដែលបានរាយការណ៍ពីលទ្ធផលនៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន បានបង្ហាញថា សកម្មភាពចរាចរជួញដូរ និងប្រើប្រាស់គ្រឿងញៀន បានកើតមាននៅ រាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, កណ្តាល, តាកែវ, កំពង់ស្ពឺ, កំពង់ឆ្នាំង, កំពង់ចាម, ព្រៃវែង, ស្វាយរៀង, ស្ទឹងត្រែង, រតនគិរី, កំពត, បាត់-ដំបង, បន្ទាយមានជ័យ, ពោធិ៍សាត់, កំពង់ធំ, ក្រចេះ, សៀមរាប និង ខេត្តត្បូងឃ្មុំ ៕

ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបបានក្នុងខែកក្កដានេះ កត់សំគាល់ឃើញមាន ៣ ករណីធំៗ ដែលក្នុងនោះ មន្ទីរប្រឆាំងគ្រឿងញៀន បង្ក្រាបបាន១ករណី, ចាប់យកមេតំហ្វេតាមីន ICE ចំនួន ៥២២,០៧ ក្រាម និងស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បង្ក្រាបបានពីរករណី, ចាប់យកមេតំហ្វេតាមីន ICE ចំនួន ៥២៨,៤០ ក្រាម និង មេតំហ្វេតាមីន ICE ចំនួន ១.១៨៦,៤០ ក្រាម ៕

# II. អំពីការងារដឹកនាំ និង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

## ១. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តណែនាំ ដឹកនាំបញ្ជា និងចូលរួមផ្ទាល់លើការងារជាគោលសំខាន់ៗ ជាអាទិ៍ :

- រៀបចំក្រុមការងារដើម្បីចុះសិក្សានិងពិភាក្សាការងារជាមួយរាជធានី-ខេត្តគោលដៅពាក់ព័ន្ធនឹង ៖
  - ✓ ការរៀបចំកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ សម្រាប់អប់រំ បន្សាប និងព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។
  - ✓ ការជំរុញអ្នកញៀនគ្រឿងញៀនឲ្យទៅទទួលយកសេវាព្យាបាល និងស្តារនីតិសម្បទា ។
  - ✓ ការរៀបចំអនុក្រឹត្យស្តីពី ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។
  - ✓ ការផលិតស្លាកសញ្ញា ដើម្បីបានដាក់បង្ហាញនៅតាមមណ្ឌលសុខភាព ដែលបានរៀបចំរួច សម្រាប់ការងារផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀន ។
- ជំរុញក្រសួងសុខាភិបាល ក្នុងការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ក្នុងរាជធានីភ្នំពេញ ។
- ជំរុញក្រសួងទេសចរណ៍ អនុវត្តអនុក្រឹត្យ លេខ ១៩១ អ.ន.ក្រ/បក ស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ និងជំរុញអនុវត្តការអប់រំបង្ការ ទប់ស្កាត់និងបង្រ្កាបឲ្យបានសកម្មថែមទៀតនូវផលិតផល ស៊ីហ្សា និង បារីអេឡិចត្រូនិច ។
- បើកវគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពជំនាញ ដល់មន្ត្រីអនុវត្តន៍ច្បាប់នៅថ្នាក់ក្រោមជាតិចាប់ពីថ្នាក់ខេត្ត រហូតដល់ ថ្នាក់ប៉ុស្តិ៍រដ្ឋបាលមូលដ្ឋាន ។
- បើកវគ្គបណ្តុះបណ្តាលកងយោធពលខេមរភូមិន្ទនៅតាមបណ្តាភូមិភាគ និងវរការពារព្រំដែន ។
- សហការជាមួយសាលាបណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីកែសម្រួលខ្លឹមសារឯកសារបណ្តុះបណ្តាលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីយុទ្ធសាស្រ្តប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន ។

## ២. អំពីលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ២.១. ការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ បដិសេធគ្រឿងញៀន

ផ្តើមចេញពីគោលការណ៍ដឹកនាំរបស់ ឯកឧត្តម ឧបនាយរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ក៏ដូចជាផែនការអនុវត្តទិសដៅការងារដែលបានដាក់ចេញកាលពីខែមិថុនា ឆ្នាំ២០១៤ កន្លងទៅ ក្រសួង-ស្ថាប័នជាសមាជិក និងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានបន្តយកចិត្តទុកដាក់អនុវត្តការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយក្នុងកម្មវិធីប្រចាំថ្ងៃ-សប្តាហ៍-ខែ, ការអប់រំនៅតាមសហគមន៍ ទទួលបានលទ្ធផលគួរកត់សំគាល់ **ដូចមានក្នុងឧបសម្ព័ន្ធទី១ ។ ក្នុងនោះ** លទ្ធផលដែលបានអនុវត្តដោយអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រួមមាន :

- អគ្គលេខាធិការ បានចូលរួមផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀន នៅក្នុង

សិក្ខាសាលាស្តីពី សភាពការណ៍គ្រឿងញៀន និងផលប៉ះពាល់ផ្សេងៗនៃឥទ្ធិពលគ្រឿងញៀនដល់សង្គម ដែលសិក្ខាសាលានេះ ធ្វើនៅសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សម្រាប់និស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន (ថ្ងៃទី ២៣.៧.២០១៤ និស្សិតចំនួន ៣០០ នាក់) ។

- អគ្គលេខាធិការរង បានចូលរួមផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀន នៅក្នុងវេទិកាសាធារណៈរបស់អង្គការទស្សនៈពិភពលោកកម្ពុជា (ថ្ងៃទី ០៤/៧/២០១៤ ខណ្ឌឫស្សីកែវ អ្នកចូលរួម ២០០ នាក់) ។
- បន្តអនុវត្តកម្មវិធីសម្រាប់ប្រិយមិត្តអ្នកអាន **សារ** អប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមគេហទំព័រ របស់ អ.ជ.ប.គ.ញ **ប្រចាំខែកក្កដា** មានប្រិយមិត្តអ្នកអានចំនួន **៣០.៦៥៨** ដង ។
- សហការជាមួយក្រុមហ៊ុន មូសាឈី អេដវឺថាយស៊ីង ខូ.អិល.ធី.ឌី ដើម្បីផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅរាជធានីភ្នំពេញ ។
- បន្តកិច្ចសហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកោះកុង ដើម្បីរៀបចំកម្មវិធីប្រឡងផ្តាច់ព្រ័ត្រ កាគូរគំនូរអប់រំពីបញ្ហាគ្រឿងញៀន ។

**ជារួម** សកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀន នៅតាមសហគមន៍ ដែលបានអនុវត្តដោយក្រសួង-ស្ថាប័ន ព្រមទាំងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន **១៧** គឺ ខេត្តកំពង់ចាម, ព្រៃវែង, ក្រចេះ, កំពង់ធំ, កោះកុង, ប៉ៃលិន, ស្វាយរៀង, កណ្តាល, តាកែវ, មណ្ឌលគិរី, កំពត, បាត់ដំបង, ស្ទឹងត្រែង, សៀមរាប, ព្រះវិហារ, កំពង់ឆ្នាំង, កំពង់ស្ពឺ នៅក្នុងខែកក្កដា ឆ្នាំ២០១៤ នេះ មានមហាជនចូលរួមប្រមាណ **៩១.៩៦៣** លើ **៣៤.២០០** នាក់ [1] នៃខែមិថុនា ឆ្នាំ ២០១៤ ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី១ ។

## ***២.២. ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ ចំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន***

- ***ការកាត់បន្ថយគ្រោះថ្នាក់***
  - ✓ អគ្គលេខាធិការ បានចូលរួមកិច្ចប្រជុំពិភាក្សាតុមូល ស្តីពីឧបសគ្គនៃការផ្តល់សេវាសុខភាព និងសង្គមដល់ក្រុមប្រឈមមុខខ្ពស់ (២២.៧.២០១៤ នៅស្ថានីយទូរទស្សន៍ជាតិកម្ពុជា) ។
  - ✓ បញ្ចប់ការរៀបចំឯកសារ គោលនយោបាយ និងគោលការណ៍ណែនាំសម្រាប់ការអនុវត្តកម្មវិធី ម្តុល / ស៊ីរ៉ាំង នៅកម្ពុជា ។
  - ✓ ចូលរួមកិច្ចប្រជុំពិភាក្សាលើការកសាងផែន ការកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន តាមការអញ្ជើញរបស់ក្រសួងសុខាភិបាល កាលពីថ្ងៃទី៦/៧/២០១៤ (អ្នកចូលរួម មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប / មន្ត្រីពាក់ព័ន្ធ ២៨ រូប) ។
  - ✓ បានផ្តល់បទបង្ហាញច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់អាជ្ញាធរមូលដ្ឋាន និងដៃគូពាក់ព័ន្ធ ក្នុង

---
[1] សកម្មភាពផ្សព្វផ្សាយអប់រំ មានការថយចុះដោយសាររដូវវស្សាកម្មវិធីប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុននានា ត្រូវផ្អាកដំណើរការបណ្តោះអាសន្ន

វគ្គបណ្តុះបណ្តាលស្តីពី ការឆ្លើយតបមេរោគអេដស៍ / ជំងឺអេដស៍តាមរយៈដៃគូសហគមន៍ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់ (ខេត្តមណ្ឌលគិរី ២៣-២៧/៦/២០១៤ មន្ត្រី ១ រូប / មន្ត្រីពាក់ព័ន្ធ ៦០ នាក់)។

- ***ការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន***
  - ✓ បានរៀបចំកិច្ចប្រជុំពិភាក្សាស្តីពីការពង្រឹងការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយផ្តោតការពិភាក្សាទៅលើការងារសំខាន់បីគឺ ការរៀបចំកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន, ការជំរុញអ្នកញៀនគ្រឿងញៀនឲ្យទៅទទួលយកសេវាព្យាបាល និងស្តារនីតិសម្បទា, ការរៀបចំអនុក្រឹត្យស្តីពីការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។
  - ✓ រៀបចំកិច្ចប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹងការពង្រឹងការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន (មន្ត្រីអគ្គលេខាធិការដ្ឋាន ២ រូប / មន្ត្រីក្រសួងពាក់ព័ន្ធ ៦ រូប) ។
  - ✓ ចូលរួមសិក្ខាសាលាអាស៊ាន ឆ្នាំ២០១៤ ស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀន ក្រោមប្រធានបទ ការព្យាបាលអ្នកញៀនគ្រឿងញៀន, បញ្ហាប្រឈម និងបរិយាកាសអំណោយផលនាពេលអនាគត (ធ្វើនៅប្រទេសថៃ ១១-១៣/៦/២០១៤ មន្ត្រីអគ្គលេខាធិការ ០១ រូប / មន្ត្រីពាក់ព័ន្ធ ០២ រូប) ។ សិក្ខាសាលានេះ បានរៀបចំអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការជំនាញ រវាងភ្នាក់ងារផ្តល់សេវាព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀន ក្នុងចំណោមបណ្តាប្រទេសសមាជិកអាស៊ាន ។

## ***២.៣. ការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់***

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់លើការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់ តាមរយៈសកម្មភាពខាងក្រោម ៖

- ✓ បើកវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ចំនួន ១២ រូប ស្តីពីការពង្រឹងសមត្ថភាពក្នុងការត្រួតពិនិត្យគ្រឿងញៀន តាមប្រព័ន្ធកុំព្យូទ័រ (CBT) ពីថ្ងៃទី០១-០៤ ខែកក្កដា ឆ្នាំ២០១៤ ។
- ✓ រៀបចំកិច្ចប្រជុំទ្វេភាគីកម្ពុជា-វៀតណាម លើកទី២ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន (ថ្ងៃទី១៤-១៧ ខែកក្កដា ឆ្នាំ២០១៤ មន្ត្រីអគ្គលេខាធិការដ្ឋាន ១២ រូប / មន្ត្រីពាក់ព័ន្ធ ១០ រូប) ។

**ដោយឡែកនៅក្រៅប្រទេស** អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាន ៖

- ✓ ចាត់បញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់ទៅទទួលវគ្គបណ្តុះបណ្តាល ស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំ នៅសាលាបណ្ឌិត្យសភានគរបាលខេត្តយូណាន ទីក្រុងគួនមិញ ប្រទេសចិន (ថ្ងៃទី០១-១៥/៧/ ២០១៤ មន្ត្រីអគ្គលេខាធិការដ្ឋាន ០៥ រូប មន្ត្រីពាក់ព័ន្ធ១០ រូប) ។
- ✓ ចាត់បញ្ជូននាយនគរបាល ០១ រូប នៃស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ ទៅធ្វើបទឧទ្ទេសនាម នៅការិយាល័យត្រួតពិនិត្យគ្រឿងញៀនតំបន់២ (ថៃ) ស្តីពីការជួញដូរគ្រឿងញៀន តាមតំបន់ព្រំដែនកម្ពុជា-ថៃ, ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែន (ធ្វើនៅខេត្តកនកេន ប្រទេសថៃ ២៤/៧/២០១៤) ។

- ✓ ចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប ទៅទទួលវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន សម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ តាមប្រព័ន្ធអេឡិចត្រូនិច (eLearning) របស់អង្គការ UNODC ពីថ្ងៃទី២៦-២៧/៦/២០១៤ នៅប្រទេសថៃ ។
- ✓ ចូលរួមជាវាគ្មិនធ្វើបទឧទ្ទេសនាមពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅក្នុងវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តនីតិវិធីព្រហ្មទណ្ឌ ចំពោះបទល្មើសពិសេសចែងក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលរៀបចំដោយក្រសួងយុត្តិធម៌ នៅខេត្តបាត់ដំបង មានសមាសភាពចូលរួមជា ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីចំណុះសាលាខេត្ត សរុបចំនួន ៥៦ រូប (ថ្ងៃទី១៦-១៨/៧/២០១៤) ។

ក្រសួងការពារជាតិ តាមរយៈគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ បានចុះសិក្សាស្រាវជ្រាវ ចងក្រងទិន្នន័យពាក់ព័ន្ធនឹងសន្តិសុខលម្ហសមុទ្រ (រួមទាំងបញ្ហាគ្រឿងញៀន) ដើម្បីរៀបចំចងក្រងរាល់ទិន្នន័យដែលទទួលបានទុកជាឯកសារសម្រាប់ប្រើប្រាស់ក្នុងសកម្មភាពអន្តរាគមន៍ ។

ទន្ទឹមនឹងការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់ មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទ បានបន្តយកចិត្តទុកដាក់ចូលរួមសហការបង្ក្រាបបទល្មើសគ្រឿងញៀន សំដៅកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម :

- បទល្មើសគ្រឿងញៀន សរុប ***១១២ ករណី*** លើ ៩៩ ករណី នៃខែមិថុនា ឆ្នាំ២០១៤
- ជនសង្ស័យ ឃាត់ខ្លួន សរុប ***៣១៧*** នាក់ លើ ២៥៤ នាក់ នៃខែមិថុនា ឆ្នា២០១៤

  ក្នុងចំនួនបទល្មើសគ្រឿងញៀន ***១១២ ករណី*** និង ជនសង្ស័យទាំង ***៣១៧ នាក់*** ខាងលើគឺ :
  - ✓ បទល្មើសគ្រឿងញៀន បង្ក្រាបដោយកងនគរបាល ***៩១ ករណី***, ជនសង្ស័យ ***២២៧ នាក់*** (ស្រី ២៧ នាក់)
  - ✓ បទល្មើសគ្រឿងញៀន បង្ក្រាបដោយកងរាជអាវុធហត្ថ ***២១ ករណី***, ជនសង្ស័យ ***៩០ នាក់*** (ស្រី *០៩* នាក់)
- ក្នុងចំនួនជនសង្ស័យពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដែលបានឃាត់ខ្លួនទាំង ៣១៧ នាក់ ខាងលើ មាន ៣ សញ្ជាតិ គឺ ខ្មែរ ៣១២ នាក់ (ស្រី ៣៤ នាក់), វៀតណាម ៤ នាក់ (ស្រី ០២ នាក់), ថៃ ០១ នាក់ (ប្រុស) ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូង រាជធានី-ខេត្ត ។
- **វត្ថុតាងគ្រឿងញៀនចាប់យក រួមមាន** មេតំហ្វេតាមីន WY ១.៥២៦,២៥ ក្រាម, មេតំហ្វេតាមីនក្រាមម្សៅ (ICE) ១៥៦៦,៧៨ ក្រាម, កេតាមីន ១,០១ ក្រាម និង ៥០០ ដប, កញ្ឆាក្រៀម ៧,៦៥ ក្រាម, សារធាតុសង្ស័យគ្រឿងញៀន ៦០,៨៦ ក្រាម ។
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន** បានចាប់យករួមមាន ម៉ូតូ ៤៦ គ្រឿង, រថយន្ត ១ គ្រឿង, ប្រាក់កម្ពុជា ៦.៥៣១.៤០០ រៀល, ប្រាក់ថៃ ២០ បាត, ប្រាក់អាមេរិក ៥១០ ដុល្លារ, ប្រាក់វៀតណាម ១០.០០០ ដុង **ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២** ។

**ដោយឡែក** ជនសង្ស័យចាប់តាមដីកា មាន ៦ ដីកា = មនុស្ស ៩ នាក់ (ស្រី២នាក់) ជនជាតិខ្មែរ ។

**ក្រៅពីការងារខាងលើ** មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តន៍ច្បាប់នានានិងតុលាការរាជធានី-ខេត្ត នៅក្នុង ខែកក្កដា ឆ្នាំ២០១៤ នេះ សរុបចំនួន ១២០ ករណី = ១៣២ សំណាក ។ ក្នុងនោះ :

- ✓ សំណាកវិជ្ជមានសារជាតុញៀន មាន ១១៨ ករណី = ១២៥ សំណាក គឺ :
  មេតំហ្វេតាមីន ICE ៩៥ សំណាក = ៧១,៩៦%,
  មេតំហ្វេតាមីន WY ២៦ សំណាក = ១៩,៦៩%
  កញ្ឆា ០១ សំណាក = ០,៧៥ %, តូលុយអែន ០១ សំណាក = ០,៧៥ %
  ហេរ៉ូអ៊ីន = ០១ សំណាក = ០,៧៥ %, កូកាអ៊ីន ០១ សំណាក = ០,៧៥ %
- ✓ សំណាកអវិជ្ជមានសារជាតុញៀន ០២ ករណី = ០៧ សំណាក

## ***២.៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ***

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម, ក្រសួងសុខាភិបាល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារជាតុគីមីផ្សំ, វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលមានច្បាប់អនុញ្ញាតឲ្យនាំចូលនៅក្នុងខែកក្កដាឆ្នាំ២០១៤នេះ មានដូចតទៅ ៖

- សារជាតុគីមីចម្រុះ សរុបមានចំនួន ***១.០៦៤.៩២៧*** គ.ក្រ ***១.១៧០*** លីត្រ និង ***៣៦*** ដប ក្នុងនោះ
  - ✓ សារជាតុគីមី ដែលចេញអាជ្ញាបណ្ណដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម មាន ៤៨៩.៧៥២ គ.ក្រ និង ៣០ លីត្រ ( ពាក់ព័ន្ធនឹងតារាងទីIV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន )
  - ✓ សារជាតុគីមី ដែលចេញអាជ្ញាបណ្ណដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មាន ៥៧៥.០០០ គ.ក្រ ១.១៤០ លីត្រ និង ៣៦ ដប ( ពាក់ព័ន្ធនឹងតារាង IV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន )
  - ✓ សារជាតុគីមី ដែលចេញអាជ្ញាបណ្ណដោយក្រសួងសុខាភិបាល មាន ១៧៥ គ.ក្រ ( ពាក់ព័ន្ធនឹងតារាង IV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន )
- វត្ថុធាតុដើម និងឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលនាំចូលដោយក្រសួងសុខាភិបាល មាន ១១ គ.ក្រ ៧៤៧ ក្រាម ៤៦០ មិល្លីក្រាម ( ពាក់ព័ន្ធនឹងតារាង II, III, IV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន )

**ជាមួយនេះ អគ្គលេខាធិការដ្ឋាន** បាន ៖

- ត្រៀមបែបបទប្រគល់ ប្រេងម្រះព្រៅភ្នំ ចំនួន ១.៧០០ លីត្រ និង ១២៣ គ.ក្រ ទៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីបន្តគ្រប់គ្រង និងចាត់ចែងតាមសមត្ថកិច្ច ។
- ជួបប្រជុំជាមួយក្រសួងសុខាភិបាល ដើម្បីពិភាក្សាពីការនាំចូល និងប្រើប្រាស់សារជាតុ Ephedrine និង Pseudo-Ephedrine ។

## ***២.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសជិតខាង***

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសម្របសម្រួលជាមួយភាគីវៀតណាម ដើម្បីជំរុញការរៀបចំកិច្ចប្រជុំទ្វេភាគីកម្ពុជា-វៀតណាម លើកទី២ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀនតាមតំបន់ព្រំដែន (BLO) ។

## ២.៦. កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសក្នុងតំបន់ និងអន្តរជាតិ

- ✓ បានសម្របសម្រួល តាមការស្នើសុំរបស់អង្គការ UNODC ដើម្បីចាត់បញ្ជូននាយនគរបាល នៃស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ ទៅធ្វើបទឧទ្ទេសនាមនៅការិយាល័យត្រួតពិនិត្យគ្រឿងញៀនតំបន់២ (ថៃ) ស្តីពីការជួញដូរគ្រឿងញៀនតាមតំបន់ព្រំដែនកម្ពុជា-ថៃ, ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែន ។
- ✓ បានសម្របសម្រួលជាមួយអង្គការ UNODC ដើម្បីចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប ទៅទទួលវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែនសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់តាមប្រព័ន្ធអេឡិចត្រូនិច (eLearning) ។
- ✓ បានសម្របសម្រួលជាមួយគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀនចិន ដើម្បីចាត់បញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់ ទៅទទួលវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំ នៅសាលាបណ្ឌិត្យសភានគរបាល ខេត្តយូណាន ប្រទេសចិន ។
- ✓ បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការជំនាញ រវាងភ្នាក់ងារផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនក្នុងចំណោមបណ្តាប្រទេសសមាជិកអាស៊ាន។

## ២.៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ដើម្បីពង្រឹងនិងពង្រីកលទ្ធភាពក្នុងការអនុវត្តយុទ្ធសាស្ត្រពហុវិស័យឲ្យមានប្រសិទ្ធភាព អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាន ៖

- ✓ បញ្ចប់ការរៀបចំអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- ✓ រៀបចំអនុក្រឹត្យស្តីពី ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។
- ✓ រៀបចំប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានសុខភាពផ្លូវចិត្តនិងការបំពានគ្រឿងញៀន។
- ✓ រៀបចំប្រកាសអន្តរក្រសួងស្តីពីការបន្សាប និងការព្យាបាលទាំងផ្លូវកាយ និងផ្លូវចិត្តអ្នកញៀនគ្រឿងញៀន ។
- ✓ បង្កើតក្រុមការងារ ដើម្បីចុះពិនិត្យនិងភាក្សាលើការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ សម្រាប់ការអប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

# III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែសីហា ឆ្នាំ២០១៤

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននឹងបន្តសម្របសម្រួល ជំរុញអនុវត្តទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

### *១. ការអប់រំ ផ្សព្វផ្សាយ បង្ការទប់ស្កាត់ និងបដិសេធគ្រឿងញៀន*

**១.១.** ស្នើសុំទៅគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តព្រះសីហនុ ដើម្បីផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីសភាអ៊ីនធឺណែតនៃស្ថានីយទូរទស្សន៍ CTN និង CNC ស្តីពីសកម្មភាព និងលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀននៅក្នុងភូមិសាស្ត្ររបស់ខេត្តព្រះសីហនុ (១៣/៨/២០១៤) ។

**១.២.** ត្រៀមចូលរួមជាវាគ្មិនក្នុងកម្មវិធី " យុវជនថ្ងៃនេះ "ក្រោមប្រធានបទ ការចូលរួមរបស់យុវជនដើម្បីទប់ស្កាត់ និងបង្ការការប្រើប្រាស់គ្រឿងញៀន (នៅអគ្គនាយកដ្ឋានវិទ្យុ និង ទូរទស្សន៍បាយ័ន ថ្ងៃទី០៤/៧/២០១៤) ។

**១.៣.** ត្រៀមរៀបចំពិធីប្រឡងផ្តាច់ព្រ័ត្រ ការគូរគំនូរស្តីពីបញ្ហាគ្រឿងញៀន នៅខេត្តកោះកុង ។

**១.៤.** បន្តកិច្ចសហការជាមួយក្រុមហ៊ុន Musashi Advertising Co., LTD ដើម្បីផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅរាជធានីភ្នំពេញ តាមរយៈការបញ្ចាំងរូបភាព និងភាពយន្តខ្លី នៅលើរថយន្តចល័ត ។

**១.៥.** បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត វិស័យឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន និងការបង្ការទប់ស្កាត់ការប្រើប្រាស់ ការធ្វើអាជីវកម្មផលិតផលស៊ីហ្សា និង បារីអេឡិចត្រូនិច នៅតាមរាជធានី-ខេត្តទូទាំងប្រទេស ។

**១.៦.** សហការជាមួយក្រសួងទេសចរណ៍ដើម្បីអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ។

**១.៧.** សហការជាមួយក្រសួងទេសចរណ៍ ដើម្បីរៀបចំផលិតបន្ថែមនូវស្ទីកឃ័រ (Sticker) ផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន អេដស៍ ការប្រើប្រាស់អាវុធ និងការជួញដូរមនុស្ស ។

**១.៨.** បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករតន្ត្រីករ និងវិស័យឯកជន ដើម្បីជំរុញការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយនានា ។

**១.៩.** បន្តជំរុញការងារបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមក្រសួង-ស្ថាប័ន រោងចក្រ សហគ្រាស និងនៅតាមសហគមន៍ ។

## ២. *ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន*

**២.១.** បន្តជំរុញក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ក្នុងការបង្កើតសេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ជាមូលដ្ឋាន (CBTx) និងជំរុញការងារនេះនៅតាមបណ្តាខេត្តគោលដៅ ។

**២.២.** រៀបចំក្រុមការងារ ដើម្បីចុះសិក្សា និងពិភាក្សាការងារជាមួយរាជធានី-ខេត្តគោលដៅ ពាក់ព័ន្ធនឹង ៖

- ការរៀបចំកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ សម្រាប់ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។
- ការជំរុញអ្នកញៀនគ្រឿងញៀនឲ្យទៅទទួលយកសេវាព្យាបាល និងស្តារនីតិសម្បទា ។

**២.៣.** រៀបចំកិច្ចប្រជុំពិភាក្សា លើការរៀបចំអនុក្រឹត្យពាក់ព័ន្ធនឹងការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន (០៦/៨/២០១៤) ។

**២.៤.** បន្តការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ដើម្បីបង្កើនការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយឱសថ មេតាដូន នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ។

**២.៥.** បន្តសហការជាមួយសាលាបណ្ឌិត្យសភានគរបាលកម្ពុជា ក្នុងការកែសម្រួលឯកសារបណ្តុះបណ្តាលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ស្តីពី យុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន ។

**២.៦.** ចុះពិនិត្យតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ សម្រាប់ព្យាបាល ស្តារនីតិសម្បទា នៅរាជធានីភ្នំពេញ, បាត់ដំបង, បន្ទាយមានជ័យ និង សៀមរាប ។

## ៣. *ការពង្រឹងប្រសិទ្ធភាពការងារអនុវត្តន៍ច្បាប់*

**៣.១.** ចាត់បញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់នៃក្រសួងពាក់ព័ន្ធ និងមន្ត្រីនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្តគោលដៅ ចំនួន ៣០ រូប ទៅទទួលវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន នៅទីក្រុងគុនមិញ ប្រទេសចិន ពីថ្ងៃទី១២ ខែសីហា ដល់ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ ។

**៣.២.** ត្រៀមទទួលសម្ភារៈ (វិទ្យុទាក់ទង) សម្រាប់ការិយាល័យ BLO ចំនួន ៥ កន្លែងនៅ ប្រកជ្រៃធំ ខេត្តកណ្តាល, ប្រកប៉ោយប៉ែត (ខេត្តបន្ទាយមានជ័យ), ប្រកដូង (ខេត្តបាត់ដំបង), ប្រកព្រំ (ខេត្តប៉ៃលិន), ប្រកចាំយាម (ខេត្តកោះកុង) ។

**៣.៣.** រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់គ្រឿងញៀន តាមប្រព័ន្ធកុំព្យូទ័រវគ្គ២ ឆ្នាំ២០១៤ (CBT) ដល់មន្ត្រីអនុវត្តន៍ច្បាប់នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានីភ្នំពេញ ចំនួន ១២ រូប ពីថ្ងៃទី០៤-០៨/៨/២០១៤ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។

**៣.៤.** ចូលរួមកិច្ចប្រជុំស្តីពីការចង្អុលបង្ហាញបច្ចេកវិទ្យាថ្មី ដែលជួយដល់ការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៥/៨/២០១៤ នៅសណ្ឋាគារសាន់វេ ។

**៣.៥.** រៀបចំវគ្គបណ្តុះបណ្តាលច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ដល់ចៅសង្កាត់ និងនាយនគរបាលប៉ុស្តិ៍រដ្ឋបាល នៅខណ្ឌឫស្សីកែវ ដង្កោ សែនសុខ ជ្រោយចង្វា និង ខណ្ឌព្រែកព្នៅ ចំនួន ៦០ រូប ពីថ្ងៃទី១៤-១៥/៨/២០១៤ ។

**៣.៦.** បន្តកិច្ចសហការរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់នានា នៅតាមខ្សែបន្ទាត់ព្រំដែន និងមន្ត្រីនៃកងយោធពលខេមរភូមិន្ទ តាមបណ្តាយោធភូមិភាគ ។

**៣.៧.** ត្រៀមរៀបចំបង្កើតក្រុមការងារទប់ស្កាត់ការចរាចរគ្រឿងញៀនឆ្លងកាត់ តាមប្រកអាកាសយានដ្ឋានអន្តរជាតិ ។

## ៤. *ការត្រួតពិនិត្យសារធាតុគីមីផ្សំ*

***៤.១.*** បន្តជំរុញក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្នុងការរៀបចំសេចក្តីព្រាងប្រកាសស្តីពី ការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ។

***៤.២.*** សិក្សាស្រាវជ្រាវនិងប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុថ្មី ដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដើម្បីដាក់បញ្ចូលទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

***៤.៣.*** បន្តជំរុញនីតិវិធីក្នុងការប្រគល់និងទទួលប្រេងម្រះព្រៅភ្នំ ចំនួន ១.៧០០ លីត្រ និង ១២៣ គ.ក្រ ទៅឲ្យក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

## ***៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង***

***៥.១.*** សម្របសម្រួលជាមួយប្រទេសជិតខាង ក្នុងការជំរុញកិច្ចប្រជុំឲ្យបានទៀងទាត់ រវាងបណ្តាខេត្តនិងខេត្តជាប់ព្រំដែន កម្ពុជា-ថៃ / កម្ពុជា-វៀតណាម / កម្ពុជា-ឡាវ ។

***៥.២.*** សម្របសម្រួលជាមួយគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀនវៀតណាម និងឡាវ ដើម្បីរៀបចំដំណើរទស្សនកិច្ចជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ ទៅកាន់ប្រទេសវៀតណាម និង ឡាវ ។

***៥.៣.*** សម្របសម្រួលជាមួយគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀនវៀតណាម ដើម្បីចាត់បញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់ ទៅទទួលវគ្គបណ្តុះបណ្តាលលើការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅប្រទេសវៀតណាម (២៤-២៩/៨/២០១៤ ។

## ***៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងអន្តរជាតិ***

***៦.១.*** សម្របសម្រួលជាមួយអង្គការ UNODC ក្នុងការរៀបចំកិច្ចប្រជុំ ស្តីពីការចង្អុលបង្ហាញបច្ចេកវិទ្យាថ្មីដែលជួយដល់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន ដែលនឹងប្រារព្ធធ្វើនៅទីក្រុងបាងកក ប្រទេសថៃ ថ្ងៃទី០៤/៨/២០១៤ ។

***៦.២.*** សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ប្រឆាំងបទល្មើសគ្រឿងញៀន នៅខេត្តព្រះវិហារ ថ្ងៃទី២៤-២៥/៨/២០១៤ (មន្ត្រី ៥០ រូប), នៅខេត្តស្ទឹងត្រែង ថ្ងៃទី២៧-២៨/៨/២០១៤ (មន្ត្រី ៥០ រូប) ។

***៦.៣.*** សម្របសម្រួលជាមួយគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀនចិន ដើម្បីចាត់បញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់ចំនួន ៣០ រូប ទៅទទួលវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន នៅប្រទេសចិន (១២/៨/-០១/៩/២០១៤) ។

***៦.៤.*** សម្របសម្រួលជាមួយអង្គការ JICA ដើម្បីចាត់បញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យបទល្មើសគ្រឿងញៀន ដែលនឹងត្រូវធ្វើនៅប្រទេសជប៉ុន នាថ្ងៃទី៣១ ខែសីហា ដល់ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៤ ។

***៦.៥.*** សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីចាត់បញ្ជូនមន្ត្រីទៅចូលរួមសិក្ខាសាលាស្តីពីកម្មវិធី Global Smart ថ្នាក់តំបន់សម្រាប់អាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ ដែលនឹងត្រូវប្រារព្ធធ្វើនៅប្រទេសមីយ៉ាន់ម៉ា នាថ្ងៃទី២០-២១/៨/២០១៤ ។

***៦.៦.*** សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីរៀបចំពិធីប្រគល់-ទទួលសម្ភារៈ សម្រាប់កម្មវិធីបណ្តុះបណ្តាលចល័តស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន ។

***៦.៧.*** សម្របសម្រួលជាមួយអង្គការ UNODC ដើម្បីរៀបចំពិធីប្រគល់-ទទួលសម្ភារៈ សម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ពីគម្រោង PATROL របស់អង្គការ UNODC ។

***៦.៨.*** សម្របសម្រួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនចិន ដើម្បីត្រៀមដំណើរទស្សនកិច្ចផ្លូវការជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ អញ្ជើញទៅសាធារណរដ្ឋប្រជាមានិតចិន ។

## ***៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ***

***៧.១.*** ជំរុញការកែសម្រួលយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

***៧.២.*** ពង្រឹងយន្តការក្នុងការអនុវត្ត ផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀនរបស់រាជធានី-ខេត្ត ជាពិសេសបណ្តាខេត្តនៅតាមព្រំដែនកម្ពុជា-ឡាវ ។

***៧.៣.*** ជំរុញការរៀបចំបង្កើតលេខាធិការដ្ឋានត្រួតពិនិត្យគ្រឿងញៀន នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តមួយចំនួន ដែលមិនទាន់បានបង្កើត ។

**អគ្គលេខាធិការ**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ

"ដើម្បីជូនជ្រាប"

- ក្រសួង សមាជិក អ.ជ.ប.គ.ញ
- ក្រសួងផែនការ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
- នាយកដ្ឋាន សរុប ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ"

- ឯកសារ